**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១៦០៤ អ.ក

ចុះថ្ងៃទី ២៤.វិច្ឆិកា.២០១៩

សាលក្រមលេខ:២៧១ "ណ"

ចុះថ្ងៃទី ០៣-កញ្ញា-២០២០

# តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្តាល បានបើកសវនាការជាសាធារណៈ នាថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០២០ ដោយមានសមាសភាពដូចតទៅៈ

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមនៃសាលាដំបូងខេត្តកណ្តាល

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ជាក្រឡាបញ្ជី

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ១៦០៤ អក ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ដែល មានជនជាប់ចោទ:

១.ឈ្មោះ [redacted] ធូក ភេទ ប្រុស អាយុ ៥៥ ឆ្នាំ សញ្ជាតខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត [redacted] ខេត្ត កណ្តាល ទីលំនៅបច្ចុប្បន្ន ភូមិ [redacted] ខេត្ត កណ្តាល ឪពុកឈ្មោះ [redacted] យ៉ិន (ស្លាប់) ម្តាយឈ្មោះ [redacted] មឿន (ស្លាប់) ប្រពន្ធឈ្មោះ [redacted] ផល្លី (ស្លាប់) មានកូន ៥នាក់ ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទ លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន ប្រព្រឹត្តនៅ ភូមិព្រែកខ្មែរ ឃុំ ស្អាងភ្នំ ស្រុក ស្អាង ខេត្ត កណ្តាល កាលពីអំឡុងខែ កញ្ញា ឆ្នាំ ២០១៩ តាមមាត្រា ២៥៥ នៃច្បាប់ភូមិបាល ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ធូក ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រិទ្ធ ភេទ ប្រុស អាយុ ៥៥ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅ ភូមិដើមចាន់ សង្កាត់ ច្បារអំពៅ ខណ្ឌ ច្បារអំពៅ រាជធានី ភ្នំពេញ ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រិទ្ធ។

***អង្គហេតុនៃរឿងមានដូចតទៅ៖***

កាលពីថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០០៥ ឈ្មោះ [redacted] ធូក និង ប្រពន្ធឈ្មោះ [redacted] ផល្លី បានលក់ដីស្រែទំហំ ៣២A ស្មើនឹង ៣២០០ (បីពាន់ពីររយ) ម៉ែត្រការ៉េ និង ដីស្រែជាប់គ្នាមួយកន្លែងទៀត ទំហំ ៥ ០០០ (ប្រាំពាន់) ម៉ែត្រការ៉េ សរុប ៨ ០០០ (ប្រាំបីពាន់) ម៉ែត្រការ៉េ ស្ថិតនៅភូមិ ព្រែកខ្មែរ ឃុំ ស្អាងភ្នំ ស្រុក ស្អាង ខេត្ត កណ្តាល ឱ្យឈ្មោះ [redacted] រិទ្ធ ភេទប្រុស អាយុ៥៥ឆ្នាំ មានកិច្ចសន្យាលក់ផ្តាច់ដីស្រែ និង លិខិតផ្ទេរសិទ្ធិកាន់កាប់ លេខ ១៥៧៨/០៥ សភ ចុះថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០០៥។ បន្ទាប់ទីទិញដីស្រែនេះ ហើយឈ្មោះ [redacted] រិទ្ធ បានធ្វើការគ្រប់គ្រងជាប់រហូត ស្រាប់តែនៅអំឡុងខែ កញ្ញា ឆ្នាំ ២០១៩ ខណៈពេលដែលឈ្មោះ [redacted] រិទ្ធ ទៅធ្វើរបងលើដីនេះ បែរជាឈ្មោះ [redacted] ធូក និង ប្រពន្ធឈ្មោះ [redacted] ផល្លី បានមករារាំងមិនអោយធ្វើ និង អះអាងថាដីទំហំ ៣២A គឺបានលក់

អោយអ្នកផ្សេងឈ្មោះ [redacted] ម៉ាឡែន ម្តងទៀតហើយ (មានកិច្ចសន្យាលក់ផ្តាច់ដីស្រែលេខ ១៥៣ /០៧ សភ និង លិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ១៥៣/០៧ ចុះថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០០៧។

បានឃើញ ដីកាដំណោះស្រាយលេខ ៩០៣ ដកដស ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល។

បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៩៨១ ដកចត ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០២០។

## នាពេលសវនាការ

-ជនជាប់ចោទ ឈ្មោះ [redacted] ធូក ឆ្លើយថា:ខ្លួនមិនដែលលក់ដីអោយឈ្មោះ [redacted] វិទូ នោះទេ គឺខ្លួនលក់ដីអោយឈ្មោះ [redacted] មុំ។ ដីរបស់ខ្លួនស្ថិតនៅភូមិព្រែកខ្មែរ ឃុំ ស្អាងភ្នំ ស្រុក ស្អាង ខេត្ត កណ្តាល។ ឈ្មោះ [redacted] មុំ ពុំបានអោយលុយគ្រប់នោះ ទេទើបខ្លួនលក់ដីនោះទៅអោយគេផ្សេងវិញ។ ខ្លួនលក់អោយឈ្មោះ [redacted] មុំ ក្នុងតម្លៃ ៤ ០០ (បួនរយ) ដុល្លារអាមេរិក តែឈ្មោះ [redacted] មុំអោយតែ ៣០០ (បីរយ)ដុល្លារអាមេរិក។ ខ្លួនលក់អោយឈ្មោះ [redacted] មុំ ដោយផ្ទាល់មាត់ពុំមានធ្វើលិខិតស្នាមអ្វីទេ។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] វិទូ ទេ. តែឈ្មោះ [redacted] មុំបានយកដីទៅលក់អោយឈ្មោះ [redacted] វិទូ។ ខ្លួនបានផ្តិតមេដៃលើឯកសារ ជាមួយឈ្មោះ [redacted] ម៉ាឡែន។

-អានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬ ជនរងគ្រោះឈ្មោះ [redacted] វិទូ ថា:ខ្លួនបានទិញ ដីស្រែមួយកន្លែង ទំហំ ៣២ អា មានទីតាំងស្ថិតនៅភូមិព្រែកខ្មែរ ឃុំ ស្អាងភ្នំ ស្រុក ស្អាង ខេត្ត កណ្តាល ពីឈ្មោះ [redacted] ធូក និង ឈ្មោះ [redacted] ផល្លី ហើយបានធ្វើកិច្ចសន្យាលក់ផ្តាច់ដីស្រែ ចុះថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០០៥ និង លិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០០៥ ហើយបានគ្រប់គ្រងដីនេះរហូតដល់បច្ចុប្បន្ន។ ក្រោយមកឈ្មោះ យ៉ិន ធូក និង ឈ្មោះ [redacted] ផល្លី បានលួចលក់ដីនេះទៅអោយឈ្មោះ [redacted] ម៉ាឡែន និង បានលួចធ្វើលិខិតផ្ទេរសិទ្ធិ កាន់កាប់និង កិច្ចសន្យាលក់ផ្តាច់ដីស្រែចុះថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០០៧។ ខ្លួនសូមតុលាការផ្តន្ទាទោសឈ្មោះ [redacted] ធូក និង ឈ្មោះ [redacted] ផល្លី តាមច្បាប់។

-មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋាន: ជនជាប់ចោទឈ្មោះ [redacted] ធូក បានលក់ដីអោយឈ្មោះ [redacted] មុំ តែគាត់បានអះអាងថា បានទទួលតែ ៣០០ (បីរយ) ដុល្លារអាមេរិក តាមពិតគាត់បានទទួលគ្រប់ចំនួនអស់ហើយ។ ក្រោយមកគាត់បែរជាលក់ដីអោយ ឈ្មោះ [redacted] ម៉ាឡែន តែឈ្មោះ [redacted] ម៉ាឡែន កូនក្តីរបស់ខ្លួន មិនបានជួប ឬ មិនអាចទាក់ទងបាននោះទេ គឺមានតែឈ្មោះ [redacted] ធូក ជាអ្នកមករារាំងទៅវិញ។ អំពើរបស់គាត់គឺជាបទល្មើសលួចលក់អចលនវត្ថុអ្នកដទៃ តាមមាត្រា២៥៥ នៃច្បាប់ភូមិបាល។ ដូចនេះស្នើសុំតុលាការផ្តន្ទាទោសតាមច្បាប់ និង ទាមទារសំណងរដ្ឋប្បវេណី ៥ ០០០ (ប្រាំពាន់) ដុល្លារអាមេរិក។

-តំណាងអយ្យការសន្និដ្ឋាន:មានភស្តុតាងលើជនជាប់ចោទ ឈ្មោះ [redacted] ធូក ពីបទលួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន ប្រព្រឹត្តនៅ ភូមិ ព្រែកខ្មែរ ឃុំ ស្អាងភ្នំ ស្រុក ស្អាង ខេត្ត កណ្តាល កាលពីអំឡុងខែ កញ្ញា ឆ្នាំ ២០១៩ តាមមាត្រា ២៥៥ នៃច្បាប់ភូមិបាល ស្នើសុំតុលាការផ្តន្ទាទោសតាមច្បាប់។



Scanned with CamScanner

-មេធាវីការពារសិទ្ធិជនជាប់ចោទសន្និដ្ឋាន: ចំពោះលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ជាក់ស្តែង គឺកូនក្តីរបស់ខ្លួនមានតែ ៣២ អា តែបែរជាមានទំហំ ៨ ០០០ (ប្រាំបីពាន់) ម៉ែត្រការ៉េ ហើយចំពោះព្រំប្រទល់ក៏ខុសគ្នាដែរ ការផ្តិតមេដៃមានតែឈ្មោះ [redacted] ធូក ពុំមានប្រពន្ធឈ្មោះ [redacted] ផល្លី នោះទេ។ ហើយចំពោះឈ្មោះ [redacted] មុំ គឺពុំបានធ្វើឯកសារអ្វីទេ។ ដូចនេះស្នើសុំតុលាការពិនិត្យភស្តុតាង និង ស្នើលើកលែងចោទប្រកាន់លើកូនក្តីរបស់ខ្លួនពីបទចោទខាងលើ។

-ជនជាប់ចោទស្នើសុំតុលាការលើកលែងចោទប្រកាន់ពីបទចោទខាងលើ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ
ក្រោយពីបានថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា:**

ក.ពិរុទ្ធភាព៖

១-តាមដីកាដំណោះស្រាយលេខ ៩០៣ ដកដស ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២០ បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ធូក ពីបទ លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន ប្រព្រឹត្តនៅ ភូមិ ព្រែកខ្មែរ ឃុំ ស្អាងភ្នំ ស្រុក ស្អាង ខេត្ត កណ្តាល កាលពីអំឡុងខែ កញ្ញា ឆ្នាំ ២០១៩ តាមមាត្រា ២៥៥ នៃច្បាប់ភូមិបាល ទៅជំនុំជម្រះ និង សម្រេចលើកលែងចោទប្រកាន់លើឈ្មោះ [redacted] ផល្លី ពីបទ លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន ប្រព្រឹត្តនៅ ភូមិ ព្រែកខ្មែរ ឃុំ ស្អាងភ្នំ ស្រុក ស្អាង ខេត្ត កណ្តាល កាលពីអំឡុងខែ កញ្ញា ឆ្នាំ ២០១៩ តាមមាត្រា ២៥៥ នៃច្បាប់ភូមិបាល ។

២-តាមចម្លើយជនជាប់ចោទ ឈ្មោះ [redacted] ធូក ឆ្លើយថា:ខ្លួនមិនដែលលក់ដីអោយឈ្មោះ [redacted] រិទ្ធ នោះទេ គឺខ្លួនលក់ដីអោយឈ្មោះ [redacted] មុំ។ ដីរបស់ខ្លួនស្ថិតនៅភូមិព្រែកខ្មែរ ឃុំ ស្អាងភ្នំ ស្រុក ស្អាង ខេត្ត កណ្តាល។ ឈ្មោះ [redacted] មុំ ពុំបានអោយលុយគ្រប់នោះទេទើបខ្លួនលក់ ដីនោះទៅអោយគេផ្សេងវិញ។ ខ្លួនលក់អោយឈ្មោះ [redacted] មុំ ក្នុងតម្លៃ ៤០០ (បួនរយ) ដុល្លារអាមេរិក តែឈ្មោះ [redacted] មុំអោយតែ ៣០០ (បីរយ)ដុល្លារអាមេរិក។ ខ្លួនលក់អោយ ឈ្មោះ [redacted] មុំ ដោយផ្ទាល់មាត់ពុំមានធ្វើលិខិតស្នាមអ្វីទេ។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] រិទ្ធ ទេ តែឈ្មោះ [redacted] មុំបានយកដីទៅលក់អោយឈ្មោះ [redacted] រិទ្ធ។ ខ្លួនបានផ្តិតមេដៃលើ ឯកសារ ជាមួយឈ្មោះ [redacted] ម៉ាឡែន។

៣-តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬ ជនរងគ្រោះឈ្មោះ [redacted] រិទ្ធ ថា:ខ្លួនបានទិញ ដីស្រែមួយកន្លែង ទំហំ ៣២ អា មានទីតាំងស្ថិតនៅភូមិព្រែកខ្មែរ ឃុំ ស្អាងភ្នំ ស្រុក ស្អាង ខេត្ត កណ្តាល ពីឈ្មោះ [redacted] ធូក និង ឈ្មោះ [redacted] ផល្លី ហើយបានធ្វើកិច្ចសន្យាលក់ផ្តាច់ដីស្រែ ចុះថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០០៥ និង លិខិតផ្ទេរសិទ្ធិកាន់កាប់ ចុះថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០០៥ ហើយបានគ្រប់គ្រងដីនេះរហូតដល់បច្ចុប្បន្ន។ ក្រោយមកឈ្មោះ [redacted] ធូក និង ឈ្មោះ [redacted] ផល្លី បានលួចលក់ដីនេះទៅអោយឈ្មោះ [redacted] ម៉ាឡែន និង បានលួចធ្វើលិខិតផ្ទេរសិទ្ធិ កាន់កាប់និង កិច្ចសន្យាលក់ផ្តាច់ដីស្រែចុះថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០០៧។ ខ្លួនសូមតុលាការផ្តន្ទាទោសឈ្មោះ [redacted] ធូក និង ឈ្មោះ [redacted] ផល្លី តាមច្បាប់។

៤-មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋាន:ជនជាប់ចោទឈ្មោះ [redacted] ធូក បានលក់ដីអោយឈ្មោះ [redacted] មុំ តែគាត់បានអះអាងថា បានទទួលតែ ៣០០ (បីរយ)



Scanned with CamScanner

ដុល្លារអាមេរិក តាមពិតគាត់បានទទួលគ្រប់ចំនួនអស់ហើយ។ ក្រោយមកគាត់បែរ ជាលក់ដីអោយ ឈ្មោះ [redacted] ម៉ាឡែន តែឈ្មោះ [redacted] ម៉ាឡែន កូនក្តីរបស់ខ្លួន មិនបានជួប ឬមិនអាចទាក់ទងបាននោះទេ គឺមានតែឈ្មោះ [redacted] ធូក ជាអ្នកមករារាំងទៅវិញ។ អំពើរបស់គាត់គឺជាបទល្មើសលួចលក់អចលនវត្ថុអ្នកដទៃ តាមមាត្រា២៥៥ នៃច្បាប់ភូមិបាល។ ដូចនេះស្នើសុំតុលាការផ្តន្ទាទោសតាមច្បាប់ និង ទាមទារសំណងរដ្ឋប្បវេណី ៥ ០០០ (ប្រាំពាន់) ដុល្លារអាមេរិក។

៥-តំណាងអយ្យការសន្និដ្ឋាន:មានភស្តុតាងលើជនជាប់ចោទ ឈ្មោះ [redacted] ធូក ពីបទលួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន ប្រព្រឹត្តនៅ ភូមិ ព្រែកខ្មែរ ឃុំ ស្អាងភ្នំ ស្រុក ស្អាង ខេត្ត កណ្តាល កាលពីអំឡុងខែ កញ្ញា ឆ្នាំ ២០១៩ តាមមាត្រា ២៥៥ នៃច្បាប់ភូមិបាល ស្នើសុំតុលាការផ្តន្ទាទោសតាមច្បាប់។

៦-មេធាវីការពារសិទ្ធិជនជាប់ចោទសន្និដ្ឋាន:ចំពោះលិខិតផ្ទេរសិទ្ធិកាន់កាប់ដី ជាក់ស្តែង គឺកូនក្តីរបស់ខ្លួនមានតែ ៣២ អា តែបែរជាមានទំហំ ៨ ០០០ (ប្រាំបីពាន់) ម៉ែត្រការ៉េ ហើយចំពោះព្រំប្រទល់ក៏ខុសគ្នាដែរ ការផ្តិតមេដៃមានតែឈ្មោះ [redacted] ធូក ពុំមានប្រពន្ធឈ្មោះ [redacted] ផល្លី នោះទេ។ ហើយចំពោះឈ្មោះ [redacted] មុំ គឺពុំបានធ្វើឯកសារអ្វីទេ។ ដូចនេះស្នើសុំតុលាការពិនិត្យភស្តុតាង និង ស្នើលើកលែងចោទប្រកាន់លើកូនក្តីរបស់ខ្លួនពីបទចោទខាងលើ។

៧-ផ្អែកតាមកិច្ចសន្យាលក់ផ្តាច់ដីស្រែ ចុះថ្ងៃទី៧ខែ១០ឆ្នាំ ២០០៥ បញ្ជាក់ថាឈ្មោះ [redacted] ធូក និង ឈ្មោះ [redacted] ផល្លី បានព្រមព្រៀងគ្នា លក់ដីស្រែ នៅភូមិ ព្រែកខ្មែរ ឃុំ ស្អាងភ្នំ ស្រុក ស្អាង ខេត្ត កណ្តា មានបណ្តោយ ១០០ម៉ែត្រ ទទឹង ៨០ម៉ែត្រ គិតជាផ្ទៃ ៨ ០០០ (ប្រាំបីពាន់)ម៉ែត្រការ៉េ អោយទៅឈ្មោះ [redacted] រិទ្ធ។

៨-ផ្អែកតាមលិខិតផ្ទេរសិទ្ធិកាន់កាប់ លេខ ១៥៧៨/០៥ ចុះថ្ងៃទី ៧ ខែ ១០ ឆ្នាំ ២០០៥ បញ្ជាក់ថាឈ្មោះ [redacted] ធូក និង ឈ្មោះ [redacted] ផល្លី បានឯកភាពព្រមព្រៀងផ្ទេរសិទ្ធិកាន់កាប់ដីមួយកន្លែងមានផ្ទៃ ៨ ០០០ (ប្រាំបីពាន់)ម៉ែត្រការ៉េជាប្រភេទ ដីស្រែ ស្ថិតនៅភូមិ ព្រែកខ្មែរ ឃុំ ស្អាងភ្នំ ស្រុក ស្អាង ខេត្ត កណ្តាល អោយឈ្មោះ [redacted] រិទ្ធ ។

៩-ផ្អែកតាមកិច្ចសន្យាលក់ផ្តាច់ដីស្រែ លេខ ១៩៣ ចុះថ្ងៃទី ៥ ខែ ៨ ឆ្នាំ ២០០៧ បញ្ជាក់បានថា ឈ្មោះ [redacted] ធូក និង [redacted] ផល្លី បានលក់ដី មានផ្ទៃ ៣២ អាអោយទៅឈ្មោះ ខឹម ម៉ាឡែន ក្នុងតម្លៃ សរុប ១៩២០ ដុល្លារអាមេរិក។

១០.ជនជាប់ចោទឈ្មោះ [redacted] ធូក បានលក់ដីអោយឈ្មោះ [redacted] រិទ្ធ រួចហើយ បែរជាលក់ដី អោយទៅឈ្មោះ [redacted] ម៉ាឡែនទៀត ដែលអំពើនេះជាបទ លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន ប្រព្រឹត្តនៅ ភូមិ ព្រែកខ្មែរ ឃុំ ស្អាងភ្នំ ស្រុក ស្អាង ខេត្ត កណ្តាល កាលពីអំឡុងខែ កញ្ញា ឆ្នាំ ២០១៩ តាមមាត្រា ២៥៥ នៃច្បាប់ភូមិបាល ។

១១-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ធូក បានធ្វើឲ្យ ប៉ះពាល់ដល់របៀបរៀបរយសាធារណៈនិង សណ្តាប់ធ្នាប់សង្គម ដូចនេះត្រូវតែទទួលខុសត្រូវ ចំពោះមុខច្បាប់ ។

១២-មានភស្តុតាង បញ្ជាក់ពីពិរុទ្ធលើជនជាប់ចោទ ឈ្មោះ [redacted] ធូក ពី បទ លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន ប្រព្រឹត្តនៅ ភូមិ ព្រែកខ្មែរ ឃុំ ស្អាងភ្នំ ស្រុក ស្អាង ខេត្ត កណ្តាល កាលពីអំឡុងខែ កញ្ញា ឆ្នាំ ២០១៩ តាមមាត្រា ២៥៥ នៃច្បាប់ភូមិបាល ។

**ខ.អំពីសំណងរដ្ឋប្បវេណី៖**

មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានទាមទារសំណងរដ្ឋប្បវេណី ៥ ០០០ (ប្រាំពាន់) ដុល្លារអាមេរិក ឱ្យកូនក្តីរបស់ខ្លួន គប្បីតុលាការពិចារណា។



Scanned with CamScanner

គ.អំពីទោសៈ

## ហេតុដូច្នេះ-តុលាការ

## សម្រេច

១.ផ្តន្ទាទោសលើ

ក.ជនជាប់ចោទឈ្មោះ [redacted] ធូក (មានសាវតាជាតិគ្រប់គ្រាន់ដូចខាង លើ) ដាក់ពន្ធនាគារកំណត់រយៈពេល ១ (មួយ) ឆ្នាំ តែទោសនេះត្រូវព្យួរ

ពីបទ លួចលក់អចលនវត្ថុដែលមិនមែនជារបស់ខ្លួន ប្រព្រឹត្តនៅ ភូមិ ព្រែកខ្មែរ ឃុំ ស្អាងភ្នំ ស្រុក ស្អាង ខេត្ត កណ្តាល កាលពីអំឡុងខែ កញ្ញា ឆ្នាំ ២០១៩ តាមមាត្រា ២៥៥ នៃច្បាប់ភូមិបាល ។

២.បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] ធូក សងសំណងទៅដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] រិទ្ធ ជាប្រាក់១០ ០០០ ០០០ (ដប់លាន) រៀល ការទាមទារលើសពីនេះ ច្រានចោល។

សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០២០ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០២០ ចំពោះមុខជនជាប់ចោទ [redacted] ធូក និង កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រិទ្ធ ទុកសិទ្ធិប្តឹងទាស់ និង ឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** | **តំណាងអយ្យការ** | **ចៅក្រមជំនុំជម្រះ**

[redacted] | [redacted] | [redacted]